# ការសំភាសន៍របស់អ្នកមីង សុខ ចាន់ណារី

កៈ អ្នកធ្វើការសំភាសន៍ គីម ម៉េង ខៈ អ្នកដែលត្រូវបានគេសំភាសន៍ សុខ ចាន់ណារី

**<u>ការសង្ខេបរបស់អ្នកមីង សុខ ចាន់ណារី</u>**

អ្នកមីង សុខ ចាន់ណារី គាត់មានអាយុ ៥៩ឆ្នាំ ក្នុងឆ្នាំ ២០១៨អ្នកមីង សុខ ចាន់ណារី ភេទស្រី។អ្នកមីង សុខ ចាន់ណារី មានកូនចំនួន ៤នាក់ មានប្រុស (២នាក់) ហើយនឹងស្រី (២នាក់)អ្នកមីង សុខ ចាន់ណារី មានបងប្អូនចំនួន ៤នាក់ មានប្រុស (២នាក់) ហើយនឹងស្រី (២នាក់)អ្នកមីង សុខ ចាន់ណារី ភូមិក្រគោលស្រុកក្រោកទេះខេត្ត ស្វាយរៀងអ្នកមីង សុខ ចាន់ណារី មានទីលំនៅនាពេលបច្ចុប្បន្ននៅភូមិក្រោកគោ សង្កាត់គីឡូរម៉ែត្រលេខ៦ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ។

កៈ
ចឹងជាដំបូងជំរាសួរលោកយាយខ្ញុំបាទមកពីរខាងសាកលវិទ្យាល័យបីបាយយូនៃសហរដ្ឋអាមេរិចហើយមានការអញ្ជើញដើម្បីមានការសំភាសន៍អ្នកមីងអំពីរពង្សប្រវត្តិតតើលោកយាយអាយអនុញ្ញាត្តិអោយសំភាសន៍អ្នកមីងពង្សប្រវត្តិលោកយាយបានដែលទេ៕

ខៈ ចាសបាន ៕

កៈ ចឹងថ្ងៃនេះគឺជាថ្ងៃដែលខ្ញុំបានសំភាសន៍អ្នកមីងគឺជាថ្ងៃទី០៥ ខែ ០៥ ( មីនា ) ឆ្នាំ២០១៨ហើយធ្វើការសំភាសន៍ដោយរូបខ្ញុំបាទឈ្មោះគីមម៉េងហើយនាក់សំភាសន៍អ្នកមីងឈ្មោះ សុខ ចាន់ណារី
ចឹងផ្តើមឈ្មោះដំបូងខ្ញុំអាចស្គាល់ឈ្មោះពេញរបស់អ្នកមីងបានដែលទេអ្នកមីង???

ខៈ ចាសបាន នាងខ្ញុំឈ្មោះ សុខ ចាន់ណារី ចាសសំរាប់ឈ្មោះ សុខ នឹងគឺគេជាឈ្មោះតារបស់ខ្ញុំហើយសំរាប់ខ្ញុំនឹងគឺខ្ញុំបានយកត្រកូលតារបស់ខ្ញុំនឹងយកមកដាក់ចឹងហាស៕

កៈ បាទហើយចឹងសំរាប់អ្នកមីងមានឈ្មោះហៅក្រៅដែលរឺទេអ្នកមីង???

ខៈ
ចាសសំរាប់ឈ្មោះក្រៅរបស់ខ្ញុំនឹងគឺគេបានហៅខ្ញុំនឹងតែអ្នកមីងសុខអ្នកមីងសុខចឹងហាស ចាស៕

កៈ បាទហើយចឹងសំរាប់អ្នកមីងគឺគេបានហៅអ្នកមីងថាអ្នកមីង សុខ បាទហើយចឹងសំរាប់អ្នកមីងសព្វថ្ងៃនឹងថាតើអ្នកមីងមានអាយុប៉ុន្មានឆ្នាំហើយអ្នកមីង???

ខ៖ ចាសសំរាប់សព្វថ្ងៃននឹងគឺខ្ញុំមានអាយុ ៥៤ ឆ្នាំ ហើយចាស៕

ក៖
បាទហើយចឹងសំរាប់អ្នកមីងមានបានចាំថ្ងៃកំណើតកើតរបស់អ្នកមីងដែលទេអ្នកមីង???

ខ៖
ចាសសំរាប់ខ្ញុំនឹងគឺខ្ញុំបានកើតនៅក្នុងជំនាន់លុនណុលហាសចាសហើយសំរាប់លុនណុលនឹងគឺមានសង្គ្រាមហាសចាសហើយសំរាប់ជំនាន់នឹងគឺខ្ញុំនៅកុមារហើយសំរាប់ខ្ញុំនឹងគឺខ្ញុំបានទៅរៀនចឹងហាសចាសហើយសំរាប់ប្អូនរបស់ខ្ញុំនឹងគឺគាត់នឹងបានទៅរៀនដែលចឹងហាសចាសហើយនៅពេលដែលប្អូនរបស់ខ្ញុំហើយនឹងខ្ញុំនឹងក៏បានឈប់រៀនហើយយើងទាំង២នាក់នឹងក៏បានរត់ទៅខេត្តស្វាយរៀងចឹងហាសចាសនិយាយទៅបានប្អូនប្រុសរបស់ខ្ញុំនឹងគឺបិនអូនអេងបានយកខ្ញុំនឹងបានមកវិញចឹងហាសចាសហើយសំរាប់ឪពុករបស់វានឹងគឺបានធ្វើការងារជាទាហ៊ាននៅព្រំដែនវៀតណាមចាសនិយាយទៅគឺគាត់បានធ្វើការងារនៅទីកន្លែងនឹងតែម្តងហាសចាសហើយសំរាប់ម្តាយរបស់ខ្ញុំនឹងគឺគាត់បានរស់នៅក្នុងផ្ទះហើយសំរាប់ប្តីរបស់ខ្ញុំនឹងគឺព្រឹកឡើងចឹងទៅគឺគាត់បានយកកូននឹងបានទៅរៀនសូត្រហើយក៏បានរត់ផ្ទះនឹងតែម្តងហាសចាសហើយសំរាប់ម្តាយរបស់ខ្ញុំនឹងគឺគាត់បាននិយាយកូនអើយកុំរត់អីណាបានចូលផ្ទះមកហាសពីព្រោះអីនឹងគឺគេបានទំលាក់គ្រាប់បែកនៅចំមុខផ្ទះរបស់ខ្ញុំនឹងតែម្តងហាសចាសហើយសំរាប់ពេលនឹងគឺបងរបស់ខ្ញុំនឹងគឺគាត់បានតាមទាន់ហាសហើយនៅពេលដែលបងរបស់ខ្ញុំនឹងបានតាមទាន់ហើយចឹងហើយពួកយើងនឹងក៏បានជួបជុះគ្នាចឹងហាសហើយនៅពេលដែលយើងបានជុំគ្នានៅស្រុកនឹងហើយដល់ពេលនឹងយន្តហោះនឹងបានទំលាក់គ្រាប់បែកនឹងហើយពួកយើងទាំងអស់គ្នានឹងក៏បានជំលាស់មកដល់ស្វាយរៀងនឹងហាសហើយសំរាប់ពួកយើងទាំងអស់គ្នាក៏បានដេកសំរាក់នៅខេត្តស្វាយរៀងនឹងហើយសំរាប់ពួកពោលពតនឹងគឺគេបានចេះតែកេសកេសយើងមកចឹងហាសចាសហើយនៅពេលដែលយើងបានមកដល់ស្វាយហើយើនឹងអ្នកលឿងនឹងគឺថាហើយនៅពេលដែលយើងបានមកដល់សាលាអ្នកលឿងនឹងគឺគេបានចែកក្រមារក្រហមអោយមកយើងចឹងហាសហើយនៅពេលនឹងដូច១៧មេសាហាសដល់ពេលហើយចឹងទៅគឺថានឹងគឺខ្ញុំនឹងមានអាយុ១៤រឺក៏១៥ឆ្នាំហើយហាសចាសហើយសំរាប់ប៉ារបស់ខ្ញុំនឹងគឺគាត់មិនបានអោយខ្ញុំនឹងហៅគាត់ថាប៉ានោះទេគឺគាត់អោយខ្ញុំនឹងហៅគាត់នឹងថាឪពុកហាសចាសហើយនៅពេលដែលយើងហៅប៉ាចឹងពួកពោលពតនឹងសំលាប់យើងចោលចឹងហាសហើយសំរាប់ខ្ញុំពេលនឹងគឺខ្ញុំឆ្លាតណាស់ហាសហើយសំរាប់ខ្ញុំនឹងគឺខ្ញុំបងប្អូន២នាក់ស្រីទាំង២នាក់ហើយពេលនឹងគឺគេបានចែកក្រមារក្រហមហើយនៅពេលដែលគេបានចែកចឹងខ្ញុំនឹងបាននិយាយថាយើងអាចប្តូរក្រមារនឹងបានដែលរឺទេសំរាប់បងឯងយកក្រមារក្រហមហើយសំរាប់ខ្ញុំគឺខ្ញុំយកក្រមារពណ៍ខៀវហាសហើយនៅពេលដែលយើងបានប្តូរក្រមារគ្នាហើយចឹងសំរាប់ប៉ារបស់ខ្ញុំហើយនឹងម្តាយរបស់ខ្ញុំនឹងហើយនឹងខ្ញុំនឹងទាំងអស់គ្នាមានចំនួន៤នាក់ចឹងហាសគឺថាយើងបានប្តូរគ្នា

ចឹងហាសចាសហើយសំរាប់ខ្ញុំនឹងឆ្លាតដែលហាសហើយសំរាប់ប៉ារបស់ខ្ញុំនឹងគឺគាត់មិនចង់អោយខ្ញុំនឹងហៅគាត់ប៉ាប៉ានោះទេគឺគាត់អោយខ្ញុំនឹងហៅគាត់ថាឪពុកឪពុកហាសហើយសំរាប់ពួកពោលពតនឹងគឺវាតាមមើលយើងរហូតចឹងហាសចាសហើយនៅពេលដែលខ្ញុំនឹងបានយកក្រមារមកចឹងឪពុករបស់ខ្ញុំនឹងគាត់បាននិយាយថាកូនអើយប្រសិនជាកូនមិនបានមកពេលនឹងទេគឺយើងទាំងអស់គ្នានឹងត្រូវស្លាប់ទាំងអស់នឹងហាសហើយបានប្អូនរបស់ខ្ញុំនឹងបានមកពីពេលយប់ចឹងហាសចាស៕

កៈ បាទហើយចឹងសំរាបអ្នកមីងមានស្រុកកំណើតនៅទីកន្លែងណាដែលទៅអ្នកមីង???

ខៈ
ចាសសំរាប់ស្រុកកំណើតរបស់ខ្ញុំពិតប្រកដនឹងគឺនៅស្រុកស្វាយរៀងនឹងតែម្តងហាសចាស
៕

កៈ
បាទសំរាប់ស្រុករបស់អ្នកមីងមានស្រុកនៅទីន្លែងណាហើយភូមិនឹងនៅទីកន្លែងណាដែលទៅអ្នកមីង???

ខៈ ចាសំរាប់ភូមិរបស់ខ្ញុំនឹងគឺនៅភូមិក្រគោលស្រុកក្រោកទេះខេត្ត ស្វាយរៀង ចាស៕

កៈ បាទហើយចឹងសំរាប់អ្នកមីងមានបងប្អូនចំនួនប៉ុន្មាននាក់ទៅអ្នកមីង???

ខៈ ចាសសំរាប់បងប្អូនរបស់ខ្ញុំនឹងមានចំនួន ៤នាក់
គឺមានប្រុស២នាក់ហើយនឹងមានស្រីចំនួន
២នាក់ចាសហើយសំរាប់កូនរបស់ខ្ញុំនឹងមានស្រីចំនួន២នាក់ក៏ប៉ុនតែនឹងគឺគេបានរៀបអាពាហ៏ពិពាហ៏អស់ហើយចឹងហាសចាសហើយសំរាប់ខ្ញុំនឹងគឺខ្ញុំមេម៉ាយហាសតែសំរាប់កូនរបស់ខ្ញុំនឹងគឺគេបានរៀបអាពាហ៏ពិពាហ៏អស់ហើយចាស៕

កៈ បាទហើយចឹងបងប្អូនរបស់អ្នកមីងមានឈ្មោះអ្វីដែលទៅអ្នកមីង???

ខៈ
ចាសបងប្អូនរបស់ខ្ញុំនឹងគឺគាត់បានរស់នៅក្រោយសាលារៀននឹងមានចំនួន២នាក់បងប្អូនហាសហើយនៅសាលាលេខ៥នឹងមានចំនួន២នាក់ដែលចឹងហាសចាស៕

កៈ
បាទហើយចឹងសំរាប់អ្នកមីងមានបានចាំឈ្មោះរបស់បងប្អូនរបស់អ្នកមីងទាំងអស់គ្នាដែលរឺទេអ្នកមីង???

ខៈ ចាសសំរាប់ខ្ញុំនឹងគឺខ្ញុំចាំចាស៕

កៈ បាទបងប្អូនរបស់អ្នកមីងទី១គាត់មានឈ្មោះអ្វីដែលទៅអ្នកមីង???

ខៈចាសសំរាប់ប្អូនរបស់ខ្ញុំនឹងទី១គាត់មានឈ្មោះថា ពៅ
សំរាប់ប្អូនរបស់ខ្ញុំនឹងទី២គាត់មានឈ្មោះថា រ៉ា សំរាប់ប្អូនរបស់ខ្ញុំនឹងទី៣គាត់មានឈ្មោះថា អាគង់ សំរាប់ប្អូនរបស់ខ្ញុំនឹងទី៤គាត់មានឈ្មោះថា សុខ ចាន់ណារ៉ាវុធ
ចាសនឹងគឺប្អូនរបស់ខ្ញុំនឹងអាពៅហាសស្រីហើយនិយាយទៅគឺខ្ញុំនឹងហាត់ខ្លាំងណាស់ពីព្រោះអីនឹងគឺគេបានជូលយើងនឹងទៅរស់នៅខាងកោះធំហាសកាល់នឹងហើយសំរាប់ជំនាន់នឹងគឺថាយើងគ្មានបាយហូបនោះទេមានតែបបរសំរាប់ចឹងហាសហើយនៅក្នុងជំនាន់នឹងគឺគេបានជំលាស់អោយខ្ញុំនឹងទៅរស់នៅពួកពោលពតហាសហើយសំរាប់អូនឯងមានដឹងយ៉ាងមិចទេហើយនៅពេលដែលយើងទៅនឹងគឺអ្នកស្រុកនឹងគឺគេបានអាណិតយើងទៀតចឹងហាសហើយសំរាប់ខ្ញុំនឹងហាសហើយប្រសិនជាពួកកងចល័តនឹងបានមកសូមអោយគេនិយាយតាមខ្ញុំចឹងហាសចាសហើយសំរាប់គ្រួសារមួយនឹងគឺមិនដឹងយ៉ាងមិចនោះទេសំរាប់ខ្ញុំចឹងហាសចាសហើយពួកគេបានមកសួរខ្ញុំថាឪពុកហើយម្ដាយរបស់ឯងនឹងធ្វើការងារអ្វីដែលហាសហើយនៅពេលនឹងគឺខ្ញុំបាននិយាយថាឪពុកហើយនឹងម្ដាយរបស់ខ្ញុំនឹងគឺគាត់ទាំង២នាក់គឺគាត់ធ្វើស្រែចំការហើយសំរាប់យើងគ្មានធ្វើការងារអ្វីនោះទេចាសហើយប្រសិនជាយើងមិនបានឆ្លើយចឹងទេគឺគេនឹងយកយើងនឹងទៅសំលាប់ចោលហើយចាសហើយនៅពេលដែលគឺគេអោយយើងបានស្ទុងយើងក៏ស្ទុងតាមគេចឹងទៅហាសហើយនៅពេលដែលទឹកនឹងគឺហូរលឺសូរតែរូវហូរលឺសូរតែរូវគឺខ្ញុំប្រាប់អូនទៅហើយនៅពេលដែលយើងធ្វើការងារធ្វើរហូតដល់ម៉ោង១២យប់បានយើងបានបាយសំរាប់ហូបខ្ញុំប្រាប់ទៅហើយសំរាប់ខ្ញុំនឹងគឺខ្ញុំនឹងតស៊ូរខ្លាំងណាស់ហើយរាល់ថ្ងៃនឹងគឺខ្ញុំនឹងធ្វើការលាងចាន់អោយគេអូនហើយសំរាប់យើងមិនមានអ្វីធ្វើចេះតែធ្វើចឹងទៅហាសតែសំរាប់កូនរបស់ខ្ញុំនឹងគឺគេមិនអោយខ្ញុំនឹងធ្វើការងារចឹងទេតែខ្ញុំអត់មានអ្វីធ្វើចេះតែធ្វើលេងលេងចឹងទៅហាសចាសហើយនៅពេលដែលខ្ញុំនឹងធ្វើនឹងគឺដើម្បីបានលុយមកយើងបានទៅវត្តទៅវ៉ាអីចឹងហាសចាស៕

កៈ
បាទហើយចឹងសំរាប់អ្នកមីងមានបានចាំឈ្មោះឪពុកហើយម្ដាយរបស់អ្នកមីងដែលរឺទេអ្នកមីង???

ខៈ ចាសំរាប់ឈ្មោះឪពុកហើយនឹងម្ដាយរបស់ខ្ញុំនឹងគឺគាត់មានឈ្មោះថា កែវ សារុក នឹងឈ្មោះរបស់ម្ដាយរបស់ខ្ញុំហាសចាសហើយសំរាប់ឈ្មោះរបស់ឪពុកខ្ញុំនឹងគឺគាត់មានឈ្មោះថា សុខ ហៀប
ហើយសូម្បីតែនៅពេលដែលគាត់បានបែកពីពោលពតហើយគឺគាត់បានធ្វើជាប្រធានភូមិចឹងហាសហើយសំរាប់ល្ងូវនឹងគឺគាត់បានស្លាប់ចឹងហាសចាស៕

កៈ បាទហើយចឹងលោកទាំង២នាក់គាត់មានអាយុប៉ុន្មានឆ្នាំហើយសំរាប់ឆ្នាំនឹងអ្នកមីង???

ខ៖ ចាសសំរាប់ម្ដាយរបស់ខ្ញុំនឹងគឺគាត់មានអាយុ ៦៦ ឆ្នាំ ហើយសំរាប់ឪពុករបស់ខ្ញុំនឹងគឺគាត់មានអាយុ ៧២ ឆ្នាំហើយចាស៕

ក៖ បាទហើយចឹងសំរាប់ឪពុករបស់អ្នកមីងគាត់បងរបស់ម្ដាយរបស់អ្នកមីង ៦ឆ្នាំ មែនដែលទេអ្នកមីង
បាទហើយចឹងឪពុករបស់អ្នកមីងគាត់បងរបស់ម្ដាយរបស់អ្នកមីងត្រូវទេអ្នកមីង???

ខ៖
ចាសនិយាយទៅឪពុករបស់ខ្ញុំនឹងគឺបងម្ដាយរបស់អ្នកមីងពីព្រោះអីនឹងគឺគាត់ចាស់ជាងចឹងហាសចាស៕

ក៖
បាទហើយចឹងសំរាប់អ្នកមីងមានបានដឹងថាស្រុកកំណើតរបស់លោកឪពុកហើយនឹងម្ដាយរបស់អ្នកមីងនៅទីកន្លែងណាដែលទេអ្នកមីង???

ខ៖
ចាសសំរាប់ម្ដាយហើយនឹងឪពុករបស់ខ្ញុំនឹងគាត់នៅនឹងទាំងអស់គ្នាចឹងហាសហើយសំរាប់ម្ដាយរបស់ខ្ញុំនឹងគឺគាត់នៅស្រុកពៀរឈរហើយសំរាប់ឪពុករបស់ខ្ញុំនឹងគឺនៅស្រុកក្បាលថ្នលចាសមួយនៅពៀរឈរហើយមួយទៀតនៅក្បាលថ្នលចឹងហាសចាសនិយាយទៅគឺផ្លូវតែមួយនោះទេគ្រាន់តែមួយនៅខាងត្បូងថ្នលហើយនឹងមួយទៀតគឺនៅខាងជើងថ្នលចឹងហាសចាសក៏ប៉ុនតែសំរាប់ម្ដាយរបស់ខ្ញុំនឹងគឺជាកូនប្រធានភូមិហាសគឺនៅក្នុងជំនាន់ពីសង្គមហាសចាស៕

ក៖
បាទហើយចឹងសំរាប់អ្នកមីងមានបានចាំថានៅពេលដែលលោកទាំង២នាក់មាននៅជីវិតនឹងថាតើលោកទាំង២នាក់គាត់បានប្រកបមុខរបបអ្វីដែលទៅអ្នកមីង???

ខ៖
ចាសសំរាប់ឪពុករបស់ខ្ញុំនឹងកាល់នៅក្នុងជំនាន់សង្គមនឹងគឺគាត់ជាទាហ៊ានហើយគាត់មានសាក់៤នៅក្នុងជំនាន់នឹងហាសចាសហើយនិយាយទៅគាត់គឺជាទាហ៊ានហើយសំរាប់ម្ដាយរបស់ខ្ញុំនឹងគឺគាត់មិនបានធ្វើការងារអ្វីនោះទេគឺគាត់នៅតែផ្ទះនោះទេចាសនិយាយទៅគឺម្ដាយរបស់ខ្ញុំនឹងគឺគាត់ចេះធ្វើតែស្រែនោះទេចាស៕

ក៖
បាទហើយចឹងសំរាប់អ្នកមីងកាល់អ្នកមីងនៅពីក្មេងនឹងថាតើអ្នកមីងមានបានរៀនសូត្រដែលរឺទេអ្នកមីង???

ខ៖
ចាសនិយាយទៅកាល់ដែលខ្ញុំនឹងនៅពីក្មេងនឹងគឺថាខ្ញុំបានរៀនសូត្រនឹងបានត្រឹមតែថ្នាក់ទី១នោះទេចាស៕

ក៖
បាទហើយចឹងសំរាប់ថ្នាក់ទី១នឹងនៅក្នុងជំនាន់នឹងគឺគេបានហៅថាថ្នាក់នឹងជាថ្នាក់ធំមែនដែលទេអ្នកមីង???

ខ៖
ចាសនិយាយទៅកាល់នៅក្នុងជំនាន់សំរាប់ថ្នាក់ទី១នឹងគឺជាថ្នាក់ធំណាស់ហាសហើយដូចថាខ្ញុំថ្នាក់ទី១នឹងគឺខ្ញុំអាចអានបានដាច់ចឹងហាសចាស៕

ក៖
បាទហើយចឹងនៅពេលដែលអ្នកមីងបានរៀនសូត្រថ្នាក់ទី១នឹងថាតើអ្នកមីងបានរៀននៅសាលានឹងមានឈ្មោះអ្វីដែលទៅអ្នកមីង???

ខ៖ ចាសនៅពេលដែលខ្ញុំបានរៀនថ្នាក់ទី១នឹងគឺសាលានឹងមានឈ្មោះថា
សាលារៀនជំភូស
ចាសគឺសាលាជំភូសក្រោកគោយើងនឹងហាសចាសនិយាយទៅជិតទល់ដែលរបស់វៀតណាមហាសនិយាយទៅគឺនៅខេត្តស្វាយរៀងរបស់យើងចឹងហាសចាសនិយាយទៅសាលានឹងគឺនៅស្រុករបស់ខ្ញុំនឹងគឺស្រុករបស់លោកយាយខ្ញុំចឹងហាសចាសហើយនៅពេលដែលបែកពីពោលពតមកនឹងគឺខ្ញុំមិនបានរៀនទៀតនោះទេចាសរហូតមកដល់លូវនឹងហើយប្រសិនជានិយាយទៅគឺវាមានភាពឈឺចាប់ណាស់អូនអើយ៕

ក៖ បាទហើយចឹងនៅពេលដែលអ្នកមីងបានរៀននៅថ្នាក់ទី១
ថាតើអ្នកមីងគឺជាសិស្សពូកែរឺក៏ជាសិស្សមធ្យមរឺក៏ជាសិស្សខ្សោយរឺក៏យ៉ាងមិចដែលទៅអ្នកមីងអាចប្រាប់ខ្ញុំបានដែលទេអ្នកមីង???

ខ៖
ចាសនៅពេលដែលខ្ញុំរៀនថ្នាក់ទី១នឹងគឺខ្ញុំនឹងគឺជាសិស្សមធ្យមនោះទេនិយាយទៅគឺខ្ញុំរៀនលោកហាសចាសហើយសូម្បីតែជាប់ក្អែលនឹងក៏គេវៃយើងដែលចឹងហាសចាសហើយនៅពេលដែលគេវៃយើងនឹងគឺគេបានអោយយើងនឹងបានលាដៃហើយគេវៃលើសូតែឆ្វាបចឹងម៉ងហាសចាសហើយនៅពេលដែលលោកបានវៃចឹងដាច់គុណអើយខ្ញុំកាណាឈប់ហើយចាសហើយពេលគាត់ក៏បានឈប់វៃយើងហើយយើងក៏បានឈប់ចឹងហាសចាស៕

កៈ
បាទហើយចឹងនៅពេលដែលអ្នកមីងរៀនបានជាសិស្សមធ្យមចឹងថាតើអ្នកមីងពូកែខាងភាសាអ្វីដែលខ្លះទៅអ្នកមីង???

ខៈ
ចាសនៅពេលដែលខ្ញុំបានរៀនថ្នាក់ទី១នឹងគឺខ្ញុំរៀនបានតែអក្សរហើយនឹងលេខតែមួយមុខចឹងហាសចាសហើយសំរាប់ការងារនៅក្នុងផ្ទះនឹងគឺខ្ញុំចេះមួយចប់ចឹងហាចាសហើយសំរាប់ខ្ញុំនឹងគឺខ្ញុំបាបរែកទឹកនឹងគឺដាក់ពេញពេញពាងចាសហើយសំរាប់ឪពុកហើយនឹងម្ដាយរបស់ខ្ញុំនឹងគឺគាត់ទាំង២នាក់ស្រលាញ់ខ្ញុំណាស់ចាស៕

កៈ
បាទហើយចឹងនៅពេលដែលអ្នកមីងបានរៀនសូត្របានមធ្យមចឹងថាតើសំរាប់ផ្ទះរបស់អ្នកមីងឆ្ងាយពីសាលារៀនដែលទេអ្នកមីង???

ខៈ
ចាសនិយាយទៅពីសាលារៀនរបស់ខ្ញុំនឹងគឺវានៅជិតនោះទេហើយប្រសិនជានិយាយទៅវាពីនេះដល់ដូចជាដំបូលក្របាមចឹងហាសចាសហើយនិយាយទៅវាជិតនោះទេហើយនៅជិតនឹងគឺថាវាជិតដល់ជំភូសរបស់យើងចឹងហាសចាសហើយវាជិតសាលារៀនជំភូសនឹងតែម្ដងហាសចាស៕

កៈ
បាទហើយចឹងនៅពេលដែលអ្នកមីងរៀននឹងថាតើអ្នកមីងមានអ្វីធ្វើដំណើលទៅសាលារៀនដែលទេអ្នកមីងរឺក៏ដើលទៅរៀនរឺក៏យ៉ាងមិចដែលអ្នកមីង???

ខៈ
ចាសនៅពេលដែលខ្ញុំនឹងបានទៅរៀននឹងគឺខ្ញុំនឹងបានដើរទៅរៀននោះទេគឺគ្មានអ្វីសំរាប់នឹងជិះទៅសាលារៀននោះទេចាសហើយអាដូចថាបងប្អូនរបស់ខ្ញុំនឹងទៅរៀនជាមួយនឹងគ្នាចឹងហាសចាសហើយនិយាយទៅគឺខ្ញុំមិនចេះជិះកង់នោះទេចាសហើយពេលនឹងគឺថាឪពុកម្ដាយរបស់ខ្ញុំនឹងគឺគាត់ចង់ទិញកង់អោយខ្ញុំសំរាប់ទុក្ខជិះទៅរៀនក៏ប៉ុនតែនឹងគឺខ្ញុំបាននិយាយថាខ្ញុំមិនចេះជិះកង់នោះទេចាសហើយនៅពេលដែលខ្ញុំនឹងគឺខ្ញុំពរប្អូនរបស់ខ្ញុំនឹងទៅរៀនហើយនៅពេលដែលត្រឡប់មកវិញនឹងក៏ខ្ញុំបានពរប្អូនរបស់ខ្ញុំនឹងមកវិញដែលចឹងហាសចាសហើយនៅពេលដែលខ្ញុំនឹងបានត្រឡប់មកពីរៀនហើយចឹងគឺខ្ញុំនឹងបានយកក្របីនឹងទៅមើលហើយនៅពេលដែលយកក្របីទៅមើលហើយគឺខ្ញុំបានទៅដាំបាយទៀតហើយដាំបាយហើយខ្ញុំទៅរែកទឹកហើយនៅពេលដែលរែកទឹកនឹងគឺរែកទឹកនឹងនៅឯងវ៉ាល់ស្រែហាសចាសហើយនៅពេលដែលរែកទឹកហើយគឺខ្ញុំនឹងបានទៅស្ទូងហើយនៅពេលដែលស្ទូងហើយគឺខ្ញុំបានដាក់អីវ៉ាន់នឹងនៅផ្ទះរបស់គេទៀតហាសចាសហើយនិយាយទៅគឺខ្ញុំនឹងមិនបាន

ទំនេរនោះទេគឺសំរាប់ខ្ញុំនឹងគឺខ្ញុំនឿយណាស់ក៏ប៉ុនតែធ្វើយ៉ាងមិចយើងចេះតែខំចឹងទៅហាសចាស៕

កៈ
បាទហើយចឹងសំរាប់អ្នកមីងនៅពេលដែលអ្នកមីងបានធ្វើការងារច្រើនចឹងថាតើប្តីរបស់អ្នកមីងគាត់មានជួយការងាររបស់អ្នកមីងដែលទេអ្នកមីង???

ខៈ ចាសនិយាយទៅគឺខ្ញុំមានប្តីដែលហើយខ្ញុំបានប្តីនឹងគឺនៅក្នុងឆ្នាំ ១៩៧៩ ហាសចាសនិយាយទៅគាត់ជួយដែលតាហើយនៅពេលដែលគាត់បានទៅផឹកនៅផ្ទះមិត្តភក្តិរបស់គាត់នៅខាងព្រែកលាបនឹងហើយសំរាប់ប្តីរបស់ខ្ញុំនឹងគឺគាត់បងខ្ញុំនឹងប្រហែលជា២០ឆ្នាំហាសចាសហើយសំរាប់ប្អូនឯងបានឃើញរូបថតរបស់គាត់បានដឹងហាសចាសចាសពេលបានឃើញគាត់បានដឹងចាស៕

កៈ បាទហើយចឹងសំរាប់អ្នកមីងបានរៀបអាពាហ៍ពិពាហ៍នឹងឆ្នាំណាដែលអ្នកមីង???

ខៈ
ចាសសំរាប់ខ្ញុំបានរៀបអាពាហ៍ពិពាហ៍នឹងឆ្នាំនៅពេលដែលបានបែកពោលពតហើយចាសហើយនៅក្នុងជំនាន់នឹងមាសជី១០០,០០០រៀលហាសចាសនិយាយទៅគុណនឹង២ចឹងហាសចាស៕

កៈ បាទហើយចឹងសំរាប់ប្តីរបស់អ្នកមីងថាតើគាត់មានឈ្មោះអ្វីដែលទៅអ្នកមីង???

ខៈ ចាសសំរាប់ប្តីរបស់ខ្ញុំគាត់មានឈ្មោះថា សុខ សារុន
ហើយនិយាយទៅប្តីរបស់ខ្ញុំនឹងគឺមានមាឌធំណាស់ហើយនឹងមានកំពស់ខ្ពស់ហើយនឹងមានស្របល់នឹងសរហាសចាសហើយនិយាយទៅគឺគាត់មិនចេះនិយាយច្រើននោះទេចាសហើយសំរាប់គាត់ក៏មិនបានចេះជក់បារីដែលចឹងហាសចាសហើយនៅពេលដែលមិត្តភក្តិរបស់គាត់បានហៅគាត់នឹងទៅស៊ីការអីចឹងហើយគាត់បានហូបអីចឹងហាសចាសហើយសំរាប់គាត់ប្រសិនជាគាត់មិនទៅគឺគាត់នឹងមិនស្លាប់នោះទេចាសហើយនៅពេលនឹងខ្ញុំមានអាយុ៣០ឆ្នាំហើយសំរាប់លូវនឹងគឺខ្ញុំមានអាយុ៥០ឆ្នាំហើយចាស៕

កៈ បាទហើយចឹងមូលហេតុអ្វីបានជាប្តីរបស់អ្នកមីងនឹងគាត់ស្លាប់ចឹង???

ខៈ
ចាសមូលហេតុដែលប្តីរបស់ខ្ញុំនឹងគាត់ស្លាប់គឺដោយសារគាត់ខ្យលគរដែលពួកខ្ញុំនឹងបានមករស់នៅស្ពាយជ្រោយចង្វារនឹងហាសហើយសំរាប់ឪពុកហើយនឹងម្តាយរបស់ខ្ញុំនឹងហើយសំរាប់ខ្ញុំនឹងគឺខ្ញុំរស់នៅស្វាយតាតែសំរប់ឪពុកហើយម្តាយរបស់ខ្ញុំគឺអោយទៅរស់នៅនឹងចឹងហាសចាស៕

កៈ
បាទហើយចឹងនៅពេលដែលអ្នកមីងបានរៀបអាពាហ៍ពិពាហ៍ថាតើអ្នកណាដែលនែនាំបានរៀបអាពាហ៍ពិពាហ៍ជាមួយនឹងស្វាមីរបស់អ្នកមីងដែលទៅអ្នកមីងរឺក៏ឪពុកហើយនឹងម្ដាយរបស់អ្នកមីងបង្ខំរឺក៏ស្មាក់ចិត្តដែលទៅអ្នកមីង???

ខៈ
ចាសនិយាយទៅគឺពួកគាត់មិនបានបង្ខំខ្ញុំនោះទេគឺខ្ញុំជានាក់ស្មាក់ចិត្តទេចាសហើយនៅពេលដែលគេបានយករបស់របបមកចឹងហាសមានដូចជាម្លូលស្លារយកអីចឹងគឺខ្ញុំមិនបានដឹងនោះទេចាសហើយនៅពេលនឹងគឺខ្ញុំបានសួរម្ដាយរបស់ខ្ញុំថាហេតុអ្វីបានជាគេយកទាំងអស់នឹងមកច្រើនម្លេះម៉ែហើយពេលនឹងគឺម្ដាយរបស់ខ្ញុំបាននិយាយថាខ្ញុំនឹងលួង់មែនគឺគេយកចូលដណ្ដឹងយើងចឹងហាសហើយនៅពេលនឹងគឺខ្ញុំកំពុងតែអង្គុយលក់អន្សំមចឹងហាសចាសនឹងគឺជាប្រវត្តិរបស់ខ្ញុំចឹងហាសអង្គុយលក់អន្សំមនឹងគឺបានប្ដូរយកអង្ករនឹងបានមួយកំប៉ុងចឹងហាសចាសហើយប្រសិនជានិយាយទៅគឺខ្ញុំកំសត់ខ្លាំងណាស់ចាស៕

កៈ
បាទហើយចឹងនៅពេលដែលអ្នកមីងបានរៀបអាពាហ៍ពិពាហ៍ហើយចឹងថាតើអ្នកមីងមានកូមចំនួនប៉ុន្មាននាក់ដែលទៅអ្នកមីង???

ខៈ
ចាសសំរាប់ខ្ញុំនៅពេលដែលខ្ញុំបានរៀបអាពាហ៍ពិពាហ៍ហើយប្រសិនជានៅរស់មានចំនួន៤នាក់ចាសក៏ប៉ុន្តែកូនរបស់ខ្ញុំនឹងក៏បានរលូតមួយហើយមួយទៀតគេបានស្លាប់មួយហើយនឹងនៅរស់២នាក់ចឹងហាសហើយសំរាប់កូនរបស់ខ្ញុំនឹងនៅរស់នៅសុទ្ធតែស្រីហើយស្អាតស្អាតហាសចាស៕

កៈ
បាទហើយចឹងសំរាប់រាល់ថ្ងៃនឹងថាតើកូនរបស់អ្នកមីងគាត់នៅរៀនសូត្ររឺក៏ពួកគាត់ធ្វើការងារដែលទៅអ្នកមីង???

ខៈ ចាសសំរាប់កូនរបស់ខ្ញុំនឹងគឺគេធ្វើការងារទាំង២នាក់បងប្អូនរបស់គេចឹងហាសចាស៕

កៈ បាទហើយសំរាប់កូនរបស់អ្នកមីងពួកគាត់ធ្វើការងារនៅម្ដុំណាដែលទៅអ្នកមីង???ៗ

ខៈ
ចាសប្រសិនជានិយាយទៅគឺកូនរបស់ខ្ញុំនឹងធ្វើការងារនៅខាងក្រោយម្ដុំផ្ទះរបស់ខ្ញុំនឹងហាសចាស៕

ក៖
បាទហើយសំរាប់កូនរបស់អ្នកមីងពួកគាត់ដែលបានមកលេងអ្នកមីងដែលរឺទេអ្នកមីង???

ខ៖
ចាសកូនរបស់ខ្ញុំពួកគាត់មកលេងខ្ញុំតាចាសនិយាយទៅពេលដែលមានបុណ្យទានអីនឹងគឺគេបានមកលេងខ្ញុំហើយចាស៕

ក៖
បាទក៏ប៉ុនតែសំរាប់កូនរបស់អ្នកមីងគាត់ធ្វើការងារនៅជិតជិតនឹងពួកគាត់មិនបានមកលេងអ្នកមីងទេមែនដែលទេអ្នកមីង???

ខ៖
ចាសនិយាយទៅគឺពួកគេមិនបានមកលេងនឹងខ្ញុំនោះទេចាសពីព្រោះអីនឹងគឺពួកគេរវល់ធ្វើការងារចឹងហាសចាស៕

ក៖
បាទហើយចឹងយើងនិយាយពីជំនាន់ពោលពតវិញចឹងហាសបាទហើយចឹងសំរាប់នៅក្នុងជំនាន់ពោលពតនឹងថាតើសំរាប់អ្នកមីងបានរស់នៅទីកន្លែងណាដែលទៅអ្នកមីង???

ខ៖
ចាសនៅក្នុងជំនាន់ពោលពតនឹងគឺខ្ញុំបានរស់នៅស្រុកកោះធំហាសចាសហើយនៅឃុំត្បូងពេជ្រហើយនិយាយទៅស្រុករបស់ខ្ញុំនឹងគឺនៅខាងក្រោយស្ពានកោះធំយើងនឹងហាសចាសហើយសំរាប់អូនឯងស្គាល់ដែលទេមើលទៅអូនឯងមិស្គាល់នោះទេនៅជំនាន់របស់ខ្ញុំបានស្គាល់ហើយនៅពេលដែលនៅទីកន្លែងនឹងគឺស្រួលណាស់ហើយសំរាប់ម្ចាស់ផ្ទះរបស់គេគឺស្រួលខ្លាំងណាស់ចាសហើយគេបាននិយាយថាយោគយល់៤ត្រូវដើលតាមគាត់ហើយនៅពេលជំនាន់នឹងគឺខ្ញុំចេះតែឆ្លើយតាមគាត់ចឹងហាសពីព្រោះអីនឹងគឺខ្ញុំនៅក្មេងណាស់ចាសហើយសូម្បីតែមានប្តីក៏ត្រូវមានាដែលចឹងហាសចាស៕

ក៖
បាទហើយចឹងខ្ញុំចង់អោយអ្នកមីងបានប្រាប់ខ្ញុំថាអ្វីខ្លះដែលជាបញ្ហាលំបាក់សំរាប់អ្នកមីងនៅក្នុងជំនាន់ពោលពតហាសអ្នកមីងអាចប្រាប់ខ្ញុំបានដែលទេអ្នកមីង???

ខ៖
ចាសប្រសិនជានិយាយទៅគឺមានភាពពីបាក់ខ្លាំងណាស់រៀនភ្លេចមុខភ្លេចក្រោយចឹងហាសចាសហើយនៅពេលដែលើយើងមិនបានទៅរៀននឹងគឺខ្ញុំនឹងបានយំហើយនៅពេលដែលខ្ញុំនឹងបានយំគឺខ្ញុំយំរកតែម្តាយរបស់ខ្ញុំនោះទេចាសពីព្រោះអីនឹងគឺគេបានអោយយើងនឹ

ងបានរស់នៅជិតគ្រួសាររបស់យើងនោះទេគឺគេមិនអោយនៅជិតតែម្តងហាសចាសហើយសំរាប់ម្តាយរបស់ខ្ញុំនឹងគឺគាត់តែងតែលួចមកមើលខ្ញុំចឹងហាសចាសហើយនៅពេលដែលម្តាយរបស់ខ្ញុំបានលួចមកមើលខ្ញុំចឹងគឺខ្ញុំខ្លាចគេនឹងធ្វើបាបឪពុកហើយនឹងម្តាយរបស់ខ្ញុំណាស់ចឹងហើយខ្ញុំក៏បានប្រាប់អោយពួកគាត់ត្រឡប់ទៅវិញចឹងហាសចាសហើយខ្ញុំបានប្រាប់ម្តាយរបស់ខ្ញុំថាសំរាប់ខ្ញុំខ្ញុំមិនអីនោះទេសូមម្តាយកំបារម្ភអីណាគឺខ្ញុំបានប្រាប់ពួកគាត់ចឹងហាសចាសហើយនៅពេលនឹងផ្ទះរបស់ខ្ញុំដែលរស់នៅនឹងគឺតូចខ្លាំងណាស់ហើយសំរាប់ឈ្លោបនឹងគឺគេបានមើលយើងរហូតទៀតដល់ពេលចឹងហើយខ្ញុំប្រាប់ឪពុកហើយនឹងម្តាយរបស់ខ្ញុំថាខ្ញុំមិនអីនោះទេចាស៕

ក៖

បាទហើយចឹងនៅពេលដែលគេបានបំបែកអ្នកមីងចេញពីឪពុកហើយនឹងម្តាយរបស់អ្នកមីងហើយនៅក្នុងជំនាន់នឹងអ្នកមីងនៅជាកុមារភាពទៀតហើយគេមិនបានអោយអ្នកមីងនៅជាមួយនឹងឪពុកហើយនឹងម្តាយរបស់អ្នកមីងទេមែនដែលទេអ្នកមីង???

ខ៖

ចាសនៅក្នុងជំនាន់ពោលពតនឹងគឺគេមិនបានអោយខ្ញុំនឹងបានរស់នៅជាមួយនឹងឪពុកហើយនឹងម្តាយរបស់ខ្ញុំនោះទេគឺគេបានអោយខ្ញុំនឹងរស់នៅជាមួយនឹងកងកុមារចឹងហាសចាស៕

ក៖

បាទហេតុអ្វីទៅបានជាគេមិនអោយយើងរស់នៅចាមួយនឹងឪពុកហើយនឹងម្តាយរបស់យើងចឹងអ្នកមីង???

ខ៖

ចាសប្រសិនជានិយាយទៅគឺថាគឺគេមិនបានអោយយើងនឹងបានរស់នៅជាមួយនឹងឪពុកហើយនឹងម្តាយរបស់យើងនោះទេពីព្រោះអីនឹងនៅពេលដែលយើងរស់នៅជាមួយនឹងឪពុកហើយនឹងម្តាយរបស់យើងនឹងគឺនឹងសួរចំលើយយើងនឹងនៅក្នុងយប់នឹងតែម្តងចឹងហាសចាសហើយគឺនឹងសួរយើងថាម្តាយរបស់យើងហើយនឹងឪពុករបស់យើងនឹងធ្វើការងារអ្វីដែលហើយមានជាសាក់អ្វីដែលចឹងហាសគឺគេនឹងសួរយើងចឹងតែម្តងចាសហើយប្រសិនជាយើងនិយាយមិនត្រង់អីនឹងគឺគេនឹងយកយើងនឹងទៅវៃចោលហាសមិនមែលលេងសើចនោះទេចាសហើយនៅពេលនឹងគឺខ្ញុំបាននិយាយថាសំរាប់ម្តាយរបស់ខ្ញុំនឹងគឺគាត់ជាអ្នកធ្វើស្រែហើយសំរាប់ឪពុករបស់ខ្ញុំក៏គាត់ជាអ្នកធ្វើស្រែដែលចាសហើយសំរាប់ខ្ញុំមានបងប្អូនចំនួន៩នាក់ហើយនៅពេលដែលយើងនិយាយប្រាប់ចឹងហើយគឺគេឡើងមកសួរយើងទៀតហាសចាសហើយសំរាប់ជំនាន់នឹងគឺយើងនិយាយទៅគឺមិនឈ្មុះគេចឹងហាសចាសនិយាយទៅយើងនិយាយទៅស្តាប់ជាមួយនឹងពួកវាមិនបាននោះទេចាស៕

ក៖
បាទហើយចឹងនៅពេលដែលអ្នកមីងមិនបានជួបជាមួយនឹងគ្រួសាររបស់អ្នកមីងថាតើអ្នកមីងមានអារម្មណ៍យ៉ាងមិចដែលទៅអ្នកមីង???

ខ៖
ចាសសំរាប់ខ្ញុំនៅពេលដែលខ្ញុំមិនបានជួបជាមួយនឹងក្រុមគ្រួសាររបស់ខ្ញុំនឹងគឺថាខ្ញុំមានអារម្មណ៍ថាខ្ញុំទឹកភ្នែកហើយសំរាប់ឪពុកហើយនឹងម្ដាយរបស់ខ្ញុំនឹងនៅពេលដែលគាត់បានឃើញខ្ញុំបានដេកយំចឹងគាត់ក៏បានសួរមកកាន់ខ្ញុំថាហេតុអ្វីបានជាកូនឯងយំហើយនៅពេលដែលគាត់បានសួរមកកាន់ខ្ញុំហើយចឹងខ្ញុំក៏បាននិយាយទៅកាន់គាត់វិញដែលថាខ្ញុំមិនបានយំនោះទេតាមពិតគឺខ្ញុំនឹងឪពុកហើយនឹងម្ដាយរបស់ខ្ញុំនោះទេហើយសំរាប់ពួកវាគឺពួកវាមិនអោយយើងនឹងបានជួបនឹងឪពុកហើយនឹងម្ដាយរបស់យើងនោះទេចាសហើយនៅពេលដែលដល់ពេលយប់ម៉ោង១២យប់បានអោយខ្ញុំនឹងបានហូបបាយហើយនៅពេលព្រឹកនឹងម៉ោង១២អីនឹងបានអោយខ្ញុំហូបបាយទៀតចាសរហូតដល់ម៉ោង១២យប់វិញទៀតបានអោយយើងនឹងបានហូបបាយទៀតទោះបីជាយើងខ្លៀនយ៉ាងណាក៏ដោយយើងត្រូវតែទ្រាំចឹងហាសហើយនៅពេលដែលយើងបានម្ហូបហើយយើងយកអាស្លឹកកំផ្លោកនឹងយកមកដក់ពីលើនិយាយទៅជីវិតរបស់ខ្ញុំនឹងគឺកំសត់ខ្លាំងណាស់ចាសហើយសូម្បីតែប្អូនឯងនឹងក៏ស្រុតទឹកភ្នែកដែលចាសនិយាយទៅវាឈឺចាប់ណាស់ឈឺចាប់ចាសហើយនៅពេលដែលយើងបានបែកពីពេញភ្លេមនឹងគឺខ្ញុំនឹងលឿងណាស់គឺខ្ញុំបានរត់ទៅយកខោហើយនឹងអាវហើយខ្ញុំរត់យកតែរូចខ្លួនចឹងហាសហើយនឹងបានរត់ទៅរកឪពុកហើយនឹងម្ដាយរបស់ខ្ញុំនឹងតែម្ដងចាសហើយនៅពេលដែលយើងបានជួបគ្នានឹងគឺឪពុកហើយនឹងម្ដាយរបស់ខ្ញុំនឹងបានយំហើយនឹងបានអោបគ្នាទាំងអស់ចឹងហាសចាសហើយសំរាប់បងប្អូនរបស់ខ្ញុំនឹងបានជួបជុំគ្នាទាំងអស់គ្មាននាក់ណាមួយបានបែកគ្នានោះទេចាសហើយសំរាប់ម្ដាយរបស់ខ្ញុំនឹងគឺគាត់មានពោះធំដែលមានមីងពៅនឹងហាសចាសនិយាយទៅកូនពោក្រោយរបស់ម្ដាយរបស់ខ្ញុំនឹងហាសចាស៕

ក៖
បាទហើយចឹងនៅពេលដែលគេបានអោយអ្នកមីងជីកប្រលែលហើយនឹងជីកត្រនាបនឹងថាតើពួកពោពតនឹងមានបានអោយអ្នកមីងបានធ្វើការងារណាដែលពីបាក់ជាងនឹងដែលរីទេអ្នកមីង???

ខ៖
ចាសនិយាយទៅគឺពិបាក់ណាស់ចាសហើយនិយាយទៅពិបាក់ត្រូវថាគឺពួកពោលពតនឹងគឺគេបានអោយខ្ញុំនឹងចូលទៅក្នុងទឹកចឹងហាសចាសហើយពេលនឹងគឺថាពិបាក់ខ្លាំងណាស់ហើយប្រសិនជានិយាយទៅខ្ញុំចង់រឹងធ្ពេញហាសចាសហើយនៅពេលដែលខ្ញុំនឹងរងាយនឹងទោះរងាយយ៉ាងណាក៏ដោយខ្ញុំសុខចិត្តទ្រាំហាសដើម្បីទប់ទ្រណាប់ចឹងហាសហើយនៅពេ

លនឹងគឺខ្ញុំបានយំហើយនៅពេលដែលខ្ញុំយំគឺខ្ញុំសុខចិត្តទ្រាំចឹងហាសហើយប្រសិនជាយើងមិនទ្រាំនឹងធ្វើវានោះទេគឺនឹងវៃយើងចឹងហាសចាសហើយប្រសិនជានិយាយពីជំនាន់ពោលពតនឹងគឺថាសំរាប់ខ្ញុំគឺឆ្អែតតែម្តងហាសចាស៕

ក៖

បាទហើយចឹងថាតើគេមានបានអោយអ្នកមីងទៅធ្វើការងារដែលពិបាក់ជាងនឹងដែលរឺទេអ្នកមីង???

ខ៖

ចាសនិយាយទៅគឺគេបានអោយខ្ញុំនឹងទៅទុបទ្រណាប់ហើយនឹងគេបានអោយខ្ញុំនឹងទៅច្រូតស្រូវហើយគេបានអោយខ្ញុំនឹងទៅស្ទុងចឹងហាសចាស៕

ក៖

បាទហើយចឹងនៅពេលដែលគេអោយអ្នកមីងទៅស្ទុងនឹងហើយនឹងច្រូតស្រូវចឹងហាសថាតើអ្នកមីងបានជួបនឹងបញ្ហាលំបាក់អ្វីខ្លះទៀតដែលទេអ្នកមីង???

ខ៖

ចាសប្រសិនជានិយាយពីបញ្ហានឹងវាមានវាមានហើយគ្រាន់តែថានៅពេលដែលយើងបានស្ទុងមិនបានលឿងនឹងគឺគេបានស្តីអោយយើងចឹងហាសចាសហើយនៅពេលដែលយើងស្ទុងនឹងមិនបានល្អនឹងក៏គេនឹងបានស្តីអោយយើងទៀតចឹងហាសចាសហើយនិយាយទៅយើងត្រូវតែស្ទុងនឹងអោយអស់ហើយនឹងអោយហើយសំរាប់គេចឹងហាសចាសហើយសូម្បីតែខ្យងហើយនឹងក្តាមនឹងក៏គេមិនបានអោយនឹងបានរើសដែលចឹងហាស៕

ក៖

បាទហើយចឹងគ្រាន់តែខ្យងហើយនឹងក្តាមនឹងគឺគេមិនបានអោយយើងនឹងបានរើសចឹងអ្នកមីង???

ខ៖

ចាសនិយាយទៅទាល់តែគេនឹងបានអនុញ្ញាត្តិចឹងហាសបានយើងអាចរើសបានចាសហើយនិយាយទៅគឺយើងចេះតែតស៊ូរចឹងហាសពីព្រោះអីនឹងគឺថាយើងចិត្តបែកពីជំនាន់ពោលពតហើយចឹងហាសចាសហើយសំរាប់ឪពុករបស់ខ្ញុំនឹងគាត់គ្រាន់តែឈរមើលចឹងហាសគឺឈរនៅជិតលោកពូគ្រាន់តែយើងនឹងស៊ីញ៉ូភ្នែកទេហាសហើយឪពុករបស់ខ្ញុំនឹងគាត់បាននិយាយថាតស៊ូណាស់កូនណាស់ចាសហើយសំរាប់ម្តាយរបស់ខ្ញុំនឹងក៏គាត់បាននិយាយចឹងហាសចឹងហាសចាសហើយពេលនឹងយើងបានជិតបានបែកហើយនៅពេលនឹងឪពុកហើយនឹងម្តាយរបស់ខ្ញុំនឹងគឺគាត់បានរត់រកម្តាយរបស់ខ្ញុំចឹងហាសចាសហើយនៅពេលដែលយើងបានបែកពីជំនាន់ពោលពតហើយនឹងគឺថាយើងបានជួបគ្នាហើយយើងទាំងអស់បាន

យំហើយនឹងអោបគ្នាផងដែលហាសចាសហើយសំរាប់ឪពុករបស់ខ្ញុំគាត់បានរកបានតែបន្តិតបន្តួចនោះទេចាសចាសហើយនៅពេលដែលគេបានជំលាស់មកចឹងគឺថាសំរាប់ឪពុករបស់ខ្ញុំនឹងគឺគាត់បានសំរាក់នៅតាមជញ្ជាំមថ្មលចឹងហាសចាស។

ក៖
បាទហើយចឹងនៅពេលដែលអ្នកមីងបានដឹងថាគេបានជំលាស់ឪពុកហើយនឹងម្តាយរបស់អ្នកមីងនឹងនៅក្នុងឆ្នាំណាដែលរឺទេអ្នកមីង???

ខ៖ ចាសនិយាយអំពីបែកពេញយើងនឹងមែនដែលទេនិយាយទៅបែកពេញនៅក្នុងឆ្នាំ ១៩៧០ ហាសចាសដូចឆ្នាំ ១៩៧០
ចឹងហាសហើយនៅពេលដែលបែកនឹងគឺថាមានភាពមិនសូវដូចពីមុនចឹងហាសចាសហើយសំរាប់ពួកពោលពតនឹងគឺពួកវានឹងចេះតែគៀលគៀលយើងទៅចឹងហាសចាសហើយនៅពេលដែលយើងបានមកដល់ភ្នំពេញនឹងគឺថាជើងនឹងឡើងក្រហាមហើយនៅពេលនឹងគឺខ្ញុំបានរត់ទៅរកម្តាយរបស់ខ្ញុំចាសហើយសំរាប់ម្តាយរបស់ខ្ញុំនឹងគឺគាត់បាននិយាយថាសំរាប់កូនកូនឯងនឹងបានទៅណាចឹងហាសចាសហើយនៅពេលដែលបានបែកនឹងគឺថាសំរាប់ពួកពោលពតនឹងគឺគ្មាននាក់ណាមួយនៅនឹងនោះទេចាសគឺគ្មានតែម្តងគឺគេបានទៅស្រុកទាំងអស់រវឹងហើយសំរាប់ខ្ញុំហើយនឹងបងប្អូនរបស់ខ្ញុំនឹងគឺថាគ្មាននាក់បាក់បែកគ្នានោះទេចាសហើយសំរាប់ខ្ញុំមានបងប្អូនចំនួន៥នាក់ចឹងហាសចាសហើយសំរាប់បងប្អូនរបស់ខ្ញុំនឹងគឺថាមានស្រីចំនួន២នាក់ហើយនឹងប្រុសចំនួន២នាក់ហើយយើងទាំងអស់គ្នានឹងបានជុំគ្នាទាំងអស់ចឹងហាសចាស។

ក៖
បាទហើយចឹងនៅពេលដែលអ្នកមីងបានបែកគ្នានៅក្នុងជំនាន់ពោលពតនឹងចឹងសំរាប់អ្នកមីងរត់ទៅទីកន្លែងណាដែលទៅអ្នកមីងអាចប្រាប់ខ្ញុំបានដែលរឺទេអ្នកមីង???

ខ៖
ចាសនៅពេលដែលយើងបាននៅក្នុងជំនាន់ពោលពតនឹងគឺខ្ញុំនឹងបានរត់មកនៅភ្នំពេញរបស់យើងនឹងហាសចាសហើយនៅពេលដែលយើងបានមុនចេញពីភ្នំពេញនឹងគឺយើងចេះតែមកតាមគេហើយយើងចេះតែមើលគេចឹងហាសចាសហើយនៅពេលដែលយើងមិនបានទៅខាងទិសខាងលិចនោះទេហើយប្រសិនជាយើងទៅទិសខាងលិចនឹងយើងនឹងត្រូវស្លាប់ចឹងចាសហើយនៅពេលដែលបែកនឹងគឺយើងបានរត់មកទិសខាងកើតគឺយើងមិនបានរត់ទៅទិសខាងលិចនោះទេចាសហើយនៅពេលនឹងគឺគាត់បានតាមរកខ្ញុំចឹងហាសហើយនៅពេលដែលគាត់បានតាមរកខ្ញុំនឹងគឺគាត់បានរកឃើញចឹងហាសចាសហើយនិយាយទៅគឺប្រវត្តិរបស់ខ្ញុំនឹងគឺថាវាកំសត់ខ្លាំងណាស់ចាស។

ក៖
បាទហើយចឹងនៅពេលដែលអ្នកមីងបានរត់មកពីកន្លែងពោលពតនឹងហើយបទនឹងបានរត់មកដល់ភ្នំពេញនឹងថាតើសំរាប់អ្នកមីងមានបានជួបនឹងពួកពោលពតនឹងដែលជាទាហ៊ានពោលពតតាមផ្លូវដែលរឺទេអ្នកមីង???

ខ៖
ចាសប្រសិនជានិយាយទៅគឺខ្ញុំមិនបានដែលជួបនោះទេចាសហើយនៅពេលដែលខ្ញុំបានបែកនឹងគឺខ្ញុំបានជួបតែទាហ៊ានរបស់វៀតណាមនោះទេចាសហើយនៅពេលដែលយើងបានជួបនឹងទាហ៊ានរបស់ជនជាតិវៀតណាមនឹងគឺពួកគេបានអោយយើងទៅចឹងហាសចាសហើយនៅពេលនឹងពួកទាហ៊ានរបស់វៀតណាមនឹងគឺគេបានអោយបាយអោយមកយើងបានហូបចឹងហាសចាស៕

ក៖
បាទហើយចឹងសំរាប់ទាហ៊ានរបស់វៀតណាមនឹងពួកគេដែលបានធ្វើបាប់ទៅកាន់អ្នកមីងដែលរឺទេអ្នកមីង???

ខ៖
ចាសសំរាប់ទាហ៊ានរបស់ជនជាតិវៀតណាមគឺមិនបានដែលបានធ្វើបាប់យើងនោះទេចាសក៏ប៉ុនតែបែបជាទាហ៊ានរបស់ជនជាតិវៀតណាមគឺគេបានអោយបាយមកយើងសំរាប់ហូបចឹងហាសចាសហើយនៅពេលដែលគេបានអោយយើងបានហូបចឹងហាសគឺគេមិនបានអោយយើងទៅណានោះទេចាសពីព្រោះអីនឹងគឺថាគេបានទៅរំដោះប្រជាជនទៀតចឹងហាសចាសហើយសំរាប់ឪពុករបស់ខ្ញុំនឹងគឺគាត់ចេះភាសាវៀតណាមចឹងហាសហើយសំរាប់ម្តាយរបស់ខ្ញុំនឹងក៏គាត់បានចេះខ្លះចឹងហាសាចាស៕

ក៖
បាទហើយចឹងនៅពេលដែលអ្នកមីងបានបែកនៅក្នុងជំនាន់ពោលពតហើយចឹងសំរាប់អ្នកមីងបានរត់មករស់នៅភ្នំពេញហើយសំរាប់អ្នកមីងរត់មករស់នៅភ្នំពេញនឹងអ្នកមីងរស់នៅអស់រយះពេលប៉ុន្មានឆ្នាំដែលទៅអ្នកមីង???

ខ៖
ចាសនៅពេលដែលខ្ញុំបានបែកពីជំនាន់ពោលពតហើយនឹងគឺខ្ញុំរត់ទៅរស់នៅស្រុករបស់ខ្ញុំសិនចឹងហាសចាសហើយសំរាប់ខ្ញុំបានមករស់នៅភ្នំពេញនឹងគឺនៅឆ្នាំ ១៩៨៣ នោះទេចាសហើយនៅពេលដែលខ្ញុំបានរស់នៅភ្នំពេញនឹងគឺខ្ញុំមិនបានធ្វើការងារអ្វីនឹងរួចនោះទេចាស៕

ក៖ បាទហើយចឹងនៅពេលដែលអ្នកមីងបានមករស់នៅភ្នំពេញនៅក្នុងឆ្នាំ ១៩៨៣ នឹងថាតើចឹងសំរាប់អ្នកមីងបានរស់នៅទីកន្លែងណាដែលទៅអ្នកមីងអាចប្រាប់ខ្ញុំបានដែលទេអ្នកមីង???

ខ៖ ចាសនៅពេលដែលខ្ញុំបានមករស់នៅភ្នំពេញនឹងគឺថាយើងនៅអុនតាក់ចឹងហាសចាស៕

ក៖ បាទហើយចឹងនៅពេលដែលអ្នកមីងបានមករត់នៅក្នុងជំនាន់អុនតាក់នឹងថាតើសំរាប់អ្នកមីងបានប្រកមមុខរបបអ្វីដែលទៅអ្នកមីង???

ខ៖ ចាសសំរាប់ខ្ញុំនឹងនៅពេលដែលខ្ញុំបានបែកពីជំនាន់ពោលហើយនឹងគឺថាខ្ញុំសំរាប់ម្ដាយរបស់ខ្ញុំនឹងគឺគាត់ប្រកបមុខរបបវិញអន្សំមលក់ចឹងហាសចាសហើយសំរាប់ម្ដាយរបស់ខ្ញុំនឹងគឺគាត់ជាអ្នកធ្វើទាំងអស់នឹងហើយសំរាប់ឪពុករបស់ខ្ញុំនឹងគឺគាត់ជាអ្នករ៉ែតយកទៅលក់ចឹងហាសចាសហើយនៅពេលនឹងគឺយើងទាំងអស់គ្នានឹងបានទូរអូសចឹងហាសចាសហើយនិយាយទៅសំរាប់ខ្ញុំនឹងគឺខ្ញុំកំសត់ខ្លាំងណាស់ចាស៕

ក៖ បាទហើយចឹងសំរាប់សព្វថ្ងៃនឹងថាតើអ្នកមីងបានប្របកមុខរបបអ្វីដែលទៅអ្នកមីង???

ខ៖ ចាសសំរាប់សព្វថ្ងៃនឹងគឺខ្ញុំបានប្រកបមុខរបបលាងចានអោយគេដែលនៅទីកន្លែងលក់បាយចឹងហាសចាស៕

ក៖ បាទហើយសំរាប់អ្នកមីងបានធ្វើការងារនៅទីកន្លែងនឹងអស់រយះពេលប៉ុន្មានឆ្នាំប៉ុន្មានខែហើយអ្នកមីង???

ខ៖ ចាសសំរាប់ខ្ញុំគឺខ្ញុំបានធ្វើការងារនៅកន្លែងលក់បាយនឹងអស់រយះពេល៣ខែហើយចាសហើយធ្វើបានដល់ថ្ងៃ៥ខែ៥នឹងគឺបានចំនួន៣ខែហើយចាស៕

ក៖ បាទហើយចឹងខ្ញុំចង់សួរអ្នកមីងទៀតថានៅពេលដែលអ្នកមីងបានពីជំនាន់ពោលពតហើយចឹងហាសរហូតមកដល់សព្វថ្ងៃនឹងថាតើអ្នកមីងមានបទពីសោធន៍អ្វីដែលខ្លះដែលមានភាពសប្បាយសប្បាយនៅក្នុងជីវិតរបស់អ្នកមីងថាអ្នកមីងអាប្រាប់ខ្ញុំនឹងបានដែលទេអ្វីដែលសប្បាយសប្បាយសំរាប់អ្នកមីងចឹងហាសអ្នកមីង???

ខ៖
ចាសសំរាប់ខ្ញុំនឹងគឺខ្ញុំគ្មានភាពរីករាយអ្វីនោះទេគឺខ្ញុំគ្រាន់តែខ្ញុំនឹងខំប្រឹងរកលុយតែប៉ុននឹងចឹងហាសចាសហើយនៅពេលដែលខ្ញុំនឹងបានរកលុយបានចឹងគឺខ្ញុំខំប្រឹងធ្វើបុណ្យធ្វើទានចឹងហាសចាសហើយសំរាប់ខ្ញុំនៅពេលដែលខ្ញុំរកបានប៉ុនណាគឺខ្ញុំបានធ្វើបុណ្យបិនចឹងហាសចាសនិយាយទៅគឺគ្មាននោះទេចាសហើយសំរាប់ខ្ញុំនឹងគឺខ្ញុំមិនបានស្គាល់អ្នកណានោះទេតែមានអ្នកមីងម្នាក់នឹងគឺគាត់បានស្គាល់ម្ដាយរបស់ខ្ញុំនឹងចឹងទៅគឺគាត់បានលក់តួបអោយម្ដាយរបស់ខ្ញុំចឹងហាសចាស៕

ក៖
បាទហើយចឹងសំណួរដែលខ្ញុំចង់សួរទៅកាន់អ្នកមីងថាតើអ្នកមីងមានពាក្យអ្វីផ្ដែលផ្ដាំទៅកាន់កូនចៅរបស់អ្នកមីងដែលរឺទេនៅពេលដែលពួកគាត់បានលឺសំលេងរបស់អ្នកមីងហើយចឹងថាតើអ្នកមីងមានពាក្យអ្វីផ្ដែលផ្ដាំទៅកាន់កូនចៅរបស់អ្នកមីងដែលរឺទេអ្នកមីង???

ខ៖
ចាសសំរាប់កូនរបស់ខ្ញុំនឹងគឺខ្ញុំបានប្រាប់កូនរបស់ខ្ញុំថាកូនឯងសំរាប់កូនឯងបានកើតនៅភ្នំពេញចឹងហាសចាសតែសំរាប់ម្ដាយវិញគឺម្ដាយនឹងបានកើតនៅក្នុងជំនាន់ពោលពតហើយមានភាពកំសត់ហើយនឹងមានទឹកភ្នែកទឹកស្របោលចឹងហាសហើយនៅពេលដែលគឺកូនរបស់ខ្ញុំនឹងបាននិយាយថាខ្ញុំអរគុណម្ដាយហើយចឹងហាសហើយនៅពេលនឹងគឺកូនរបស់ខ្ញុំនឹងគឺគាត់បានទៅទិញទឹកក្រឡុកអោយខ្ញុំនឹងសំរាប់ហូបចឹងហាសចាសហើយនៅពេលដែលកូនរបស់ខ្ញុំបានទិញទឹកក្រឡុកអោយខ្ញុំសំរាប់ហូបចឹងហើយគឺខ្ញុំបាននិយាយជូនពរទៅកាន់កូនរបស់ខ្ញុំថាសូមអោយកូនរកស៊ីមានបានអីចឹងទៅហាសចាសនឹងសំរាប់បងគេចឹងហាសនិយាយទៅគឺខ្ញុំបានជូនពរគាត់ទាំង២នាក់នឹងហាសចាស៕

ក៖
បាទហើយចឹងសំរាប់អ្នកមីងមានពាក្យអ្វីផ្ដែលផ្ដាំទៅកាន់កូនចៅរបស់អ្នកមីងបន្ថែមទៀតដែលរឺទេអ្នកមីងសូមអោយគាត់បានចេះជួយអ្នកមីងរឺក៏មានអ្វីទៀតដែលរឺទេអ្នកមីង???

ខ៖
ចាសសំរាប់ខ្ញុំនឹងគឺគ្មានអ្វីនិយាយទៀតទេគ្រាន់តែអោយគេនឹងខំប្រឹងរកស៊ីហើយនឹងខំរៀនចឹងហាសចាសហើយសំរាប់កូនប្រសាររបស់ខ្ញុំនឹងនៅពេលដែលកូនរបស់ខ្ញុំនឹងគឺគាត់មិនបានខលមកលេងខ្ញុំនឹងគឺកូនរបស់ប្រសាររបស់ខ្ញុំនឹងបានអោយកូនរបស់ខ្ញុំនឹងបានខលទៅលេងម្ដាយចឹងហាសហើយក៏បាននិយាយហើយនិយាយទៀតថាកូនឯងខលទៅម្ដាយលេងតិចទៅចឹងរហូតចឹងហាសចាសពីព្រោះអីនឹងម្ដាយរបស់យើងនឹងគឺគាត់បានធ្វើការងារហត់អីចឹងហាសចឹងហើយសូមអោយកូននឹងបានខលទៅលេងម្ដាយចឹងហាសចាសនឹងសំរាប់កូនប្រសាររបស់ខ្ញុំចាស៕

ក៖
បាទហើយចឹងអត់អ្វីទេអ្នកមីងបាទចឹងសំរាប់ថ្ងៃនឹងគឺខ្ញុំអរគុណអ្នកមីងមែនទែនដែលបាន ផ្ដល់ការការសំភាសន៍ហើយនឹងមានការផ្ដល់យោលបល់ហើយនឹងបានពិភាក្សាជាមួយនឹង អ្នកមីង???

ខ៖
ចាសសំរាប់ខ្ញុំនឹងគឺខ្ញុំបានជួលគេចឹងហាសនៅពេលដែលបានបែកពីជំនាន់ពោលពតចឹង ហាសចាសនិយាយទៅគឺខ្ញុំតែងតែនឹកឃើញទោះបីជាពេលដែលខ្ញុំនឹងកំពុកហូបបាយក៏ ដោយចាសហើយនៅពេលដែលយើងបានជួបជាមួយនឹងគ្រួសាររបស់យើងហើយហើយ នៅពេលនឹងគឺយើងបានយំតែសំរាប់គេគឺគេមិនបានអោយយើងនឹងបានយំនោះទេចាស ហើយនៅពេលដែលយើងបានយំហើយចឹងគឺថាឪពុកហើយនឹងម្ដាយរបស់យើងថាកុំអោ យយើងនឹងយំចឹងហាសគឺគាត់បាននិយាយចឹងហាសចាសហើយសំរាប់ឪពុកហើយនឹងម្ដា យរបស់ខ្ញុំនឹងបាននិយាយនៅពេលដែលគេបានមកសួរយើងចឹងគឺយើងគ្រាន់តែឆ្លើយតែបិ ននឹងទៅបានហើយចឹងហាសចាសហើយកូនឯងកនិយាយផ្ដេសផ្ដាសចឹងហាសចាសប្រ សិនមិនជាចឹងទេគឺគេនឹងសំលាប់យើងចោលចឹងហាសចាសចឹងហើយកូនឯងប្រសិនជា គេបានសួរអីនឹងគឺកូនឯងនិយាយតាម្ដាយហើយនឹងឪពុករបស់កូនទៅវានឹងមិនអីនោះទេ ចាស៕

ក៖
បាទហើយចឹងសំរាប់ថ្ងៃនឹងគឺខ្ញុំមានតែប៉ុននឹងចឹងហាសអ្នកមីងហើយក៏ខ្ញុំអត់មានអ្វីច្រើន ដែលអ្នកមីងបាទហើយអរគុណច្រើនមែនទែណអ្នកមីងបាទហើយចឹងគឺខ្ញុំមានតែប៉ុននឹង សំរាប់ការពិភាក្សាហើយនឹងបានអោយខ្ញុំបានសំភាសន៍អ្នកមីងអំពីប្រវត្តិរបស់អ្នកមីងបាន ផងដែលបាទហើយចឹងសំរាប់ថ្ងៃនឹងគឺខ្ញុំមានតែប៉ុននឹងសំរាប់អ្នកមីងចឹងខ្ញុំអរគុណច្រើន ណាស់អ្នកមីងបាទហើយចឹងបន្ដិចទៀតនឹងខ្ញុំនឹងសេរឈ្មោះរបស់អ្នកមីងចឹងហាសអ្នកមីង ???

ខ៖
ចាសអរគុណច្រើនដូចគ្នាហើយចឹងអូនឯងយកលេខរបស់ខ្ញុំនឹងមួយទៅចឹងហាសហើយ សំរាប់លេខរបស់ខ្ញុំនឹងគឺ ០៩៦ ៣២ ៨២ ១១
ចាសហើយអូនឯងអាចខលមកកាន់ខ្ញុំបានចឹងហាសហើយសំរាប់អ្នកនៅក្នុងភូមិនឹងគឺគេ តែតែងហៅឈ្មោះខ្ញុំថាអ្នកមីង សុខ អ្នកមីង សុខ
ចឹងហាសចាសចឹងសំរាប់ថ្ងៃនឹងគឺខ្ញុំដល់ម៉ោងហើយពីព្រោះអីនឹងគឺខ្ញុំត្រូវទៅធ្វើការងារអោ យទៀតចឹងហាសគឺខ្ញុំធ្វើការងារនឹង២កន្លែងចាស៕

ក៖
បាទអត់អីទេអ្នកមីងបាទហើយសំរាប់អ្នកមីងធ្វើការងារចំនួន២កន្លែងមែនដែលទេអ្នកមីង???

ខ៖
ចាសនិយាយទៅគឺខ្ញុំធ្វើការងារ២នកន្លែងហើយសំរាប់ការងាររបស់ខ្ញុំនឹងគឺវានៅជិតគ្នាចឹងហាសចាសហើយសំរាប់ម៉ោង១កន្លះនឹងគឺខ្ញុំមកវិញហើយចាស៕

ក៖
បាទចឹងសំរាប់អ្នកមីងធ្វើការងារច្រើនដែលសំរាប់អ្នកមីងបាទហើយសំរាប់ថ្ងៃនឹងខ្ញុំមានតែប៉ុននឹងចឹងខ្ញុំជំរាបលាណាអ្នកមីងបាទអរគុណច្រើនអ្នកមីង៕